# ការយល់ដឹងមូលដ្ឋានរបស់និស្សិតថ្នាក់បរិញ្ញាបត្រលើការស្រាវជ្រាវ៖ ករណីសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

**លី តុង**
( LY Tong )
**វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម**
ទូរស័ព្ទ: ( +855 )12-250-887
អ៊ីមែល: lytongcambodia2013@gmail.com

**សេង សុធា**
( SENG Sothea )
**លេខាធិការដ្ឋានបណ្ឌិតសភាចារ្យ**
ទូរស័ព្ទ: ( +855 )17 313 314
អ៊ីមែល: sotheatesl@gmail.com

**មឿង ចំរើន**
( MOEUNG Chamroeun )
**លេខាធិការដ្ឋានបណ្ឌិតសភាចារ្យ**
ទូរស័ព្ទ: ( +855 )99-762-198
អ៊ីមែល: roeun_cham@yahoo.com

**តូច សុធារី**
( TOCH Sothiary )
**វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម**
ទូរស័ព្ទ: ( +855 )76-935-6356
អ៊ីមែល: sothiary@gmail.com

## ១. សេចក្តីផ្តើម

ក្នុងពេលបច្ចុប្បន្ន បរិបទសង្គមមានការប្រែប្រួលថ្មីៗ និងជាយុគសម័យមួយដែលពោរពេញទៅដោយទិន្នន័យ និងពត៌មាន ដូចនេះការអប់រំថ្នាក់ឧត្តមសិក្សា មានតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់សេដ្ឋកិច្ច និងសង្គមរបស់ប្រទេសនីមួយៗ ( Leng, 2010 )។ ស្របជាមួយគ្នានេះ ចក្ខុវិស័យនៃគោលនយោបាយលើការអភិវឌ្ឍចំពោះការសិក្សាស្រាវជ្រាវ ក្នុងវិស័យអប់រំរបស់ក្រសួងអប់រំយុវជន និងកីឡាកម្ពុជា ( MOEYS, 2010. p. 2 ) ក៏បានបង្ហាញពីសារៈសំខាន់នៃការសិក្សាស្រាវជ្រាវនេះផងដែរ ដោយបានលើកឡើងថា "ការស្រាវជ្រាវបានចូលរួមកសាងសមត្ថភាពធនធានមនុស្សលើចំណេះដឹង ជំនាញ សីលធម៌ ភាពច្នៃប្រឌិត នវានុវត្តន៍ និងសហគ្រិនភាព ក្នុងការពង្រីកការអភិវឌ្ឍរយៈពេលវែង សម្រាប់សង្គម និងសេដ្ឋកិច្ចកម្ពុជាក្នុងបរិបទសាកលភាវូនីយកម្ម។"

ការអប់រំនៅឧត្តមសិក្សាដើរតួនាទីយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍធនធានមនុស្ស ហេតុដូច្នេះហើយបានជាសាកលវិទ្យាល័យនានាលើពិភពលោក រួមទាំងកម្ពុជាផងដែរ បានបន្តខិតខំក្នុងការធ្វើនវានុវត្តន៍ទៅលើគុណភាពនៃការបង្រៀន និងការសិក្សារបស់និស្សិតនៅថ្នាក់ឧត្តមសិក្សា ( Kaing, 2017 )។ ក្រោយឆ្នាំ១៩៩០ ព្រមទាំងការអនុវត្តគោលនយោបាយទីផ្សារសេរីនិងបើកចំហ កម្ពុជាបានផ្តោតសំខាន់ទៅលើគុណភាពនៃការអប់រំកម្រិតឧត្តមសិក្សា នៅតាមសកលវិទ្យាល័យរដ្ឋ ក៏ដូចជាសាកលវិទ្យាល័យឯកជននានាដែលមានស្រាប់។ ការបង្រៀននៅវិស័យឧត្តមសិក្សា គឺស្ថិតក្នុងការផ្លាស់ប្តូរមួយដ៏សំខាន់ដោយបានចាកចេញពីសកម្មភាពដែលផ្អែកលើការបង្រៀនសុទ្ធសាធ មករួមបញ្ចូលជាមួយនិងសកម្មភាពការសិក្សាស្រាវជ្រាវ ( Jusoh & Abidin, 2012 )។

ការស្រាវជ្រាវ និងការបង្រៀនគឺមានទំនាក់ទំនងគ្នាចាំបាច់ ក្នុងការពិនិត្យឱ្យបានម៉ត់ចត់។ កន្លងមក មានការសិក្សាស្រាវជ្រាវជាច្រើនបានបង្ហាញអំពីអត្ថប្រយោជន៍ផ្តល់ទៅឱ្យសិស្សក្នុងការក្លាយខ្លួនជាអ្នកចូលរួមយ៉ាងសកម្មលើកិច្ចការស្រាវជ្រាវ (Brew, 2003; Healey, 2005; Le Heron, Baker & McEwen, 2006; Robertson & Bond, 2005 as cited in Hajdarpasic, Brew & Popenici, 2011). ជាឧទាហរណ៍ ការស្រាវជ្រាវមួយបានបង្ហាញថា ការសិក្សាដោយផ្អែកទៅលើការស្រាវជ្រាវ ជាមធ្យោបាយដ៏មានប្រសិទ្ធភាព ក្នុងការបញ្ចូលការបង្រៀនដែលមានការគាំទ្រដោយការស្រាវជ្រាវ (Healey, Jordan, Pell & Short, 2010 as cited in Hajdarpasic, Brew & Popenici, 2011)។ ហេតុដូចច្នេះ ចំណេះដឹងលើវិធីសាស្ត្រស្រាវជ្រាវពិតជាមានសារៈសំខាន់សម្រាប់និស្សិតក្នុងការពង្រីកចំណេះដឹងពួកគេ សម្រាប់ការអប់រំនៅសតវត្សទី២១នេះ។

ផ្អែកតាមការសង្កេតផ្ទាល់របស់អ្នកស្រាវជ្រាវដែលជាសាស្ត្រាចារ្យ និងធ្លាប់ជាបុគ្គលិកធ្វើការក្នុងវិស័យឧត្តមសិក្សាក្នុងប្រទេសកម្ពុជា យើងបានឃើញថា និស្សិតកម្ពុជាអាចមានកាលានុវត្តភាពច្រើនពីចំណេះដឹងទាក់ទងនិងការស្រាវជ្រាវក្រោយការបញ្ចប់ថ្នាក់ឧត្តមសិក្សា ដោយពួកគេអាចទទួលបានឱកាសក្នុងការបន្តថ្នាក់ក្រោយឧត្តមសិក្សាទាំងក្នុង និងក្រៅប្រទេស ហើយលើសពីនេះ ចំណេះដឹងលើការស្រាវជ្រាវក៏បានផ្តល់នូវជំនាញចម្រុះជាច្រើនផ្សេងៗទៀត ដែលមានសារៈសំខាន់សម្រាប់យកទៅអនុវត្តក្នុងការងាររបស់ពួកគេ។ ការសង្កេតនេះមានលក្ខណៈស្របគ្នាទៅនឹងការអះអាងដោយផ្អែកលើលទ្ធផលនៃការស្រាវជ្រាវរបស់ Foskett, Roberts and Maringe (2006) ដែលបានលើកឡើងថា សិស្សអាចទាញប្រយោជន៍ពីការសិក្សាស្រាវជ្រាវដោយមាន បណ្តុះជំនាញកាន់តែស៊ីជម្រៅ និងពហុជំនាញ (Critical and Interdisciplinary Approach) ក្នុងការបំពេញតម្រូវការរបស់និយោជក។

## ១.១. ចំណោទបញ្ហានៃការស្រាវជ្រាវ

នៅកម្ពុជា ការសិក្សាស្រាវជ្រាវគឺនៅមានភាពថ្មីទាំងការអនុវត្តក៏ដូចជាវប្បធម៌។ ជាក់ស្តែងពីឆ្នាំ ១៩៧៩ ដល់ ២០០៩ ការអប់រំកម្រិតឧត្តមសិក្សានៅកម្ពុជាមិនទាន់បានបង្កើតជាគោលនយោបាយសិក្សាស្រាវជ្រាវ និងគុណភាពនៃការសិក្សាស្រាវជ្រាវនោះទេ ហើយគោលនយោបាយ និងយុទ្ធសាស្ត្រលើការស្រាវជ្រាវ (ឆ្នាំ២០១១ ដល់ ២០១៥) របស់ក្រសួងអប់រំកម្ពុជាទើបតែត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៩ ក្នុងគោលបំណងឆ្លើយតបទៅនឹងការអភិវឌ្ឍក្នុងតំបន់និងសកលលោក (Eam, 2017)។

ឆ្លើយតបទៅនឹងសារៈសំខាន់និងតម្រូវការនៃការយល់ដឹងលើការស្រាវជ្រាវនេះហើយ បានជាគេសង្កេតឃើញថាមុខវិជ្ជាសិក្សាអំពីវិធីសាស្ត្រស្រាវជ្រាវ តែងតែត្រូវបានបញ្ចូលក្នុងមុខវិជ្ជាសិក្សាតាំងពីថ្នាក់បរិញ្ញាបត្ររហូតដល់ថ្នាក់ក្រោយឧត្តមសិក្សា ដែលវាហាក់បានក្លាយជាមូលហេតុមួយក្នុងការធ្វើឱ្យនិស្សិតកម្ពុជាមានចំណេះដឹងលើការស្រាវជ្រាវ ចាប់តាំងពីមូលដ្ឋានគ្រឹះ រហូតដល់ការអនុវត្ត និងការសរសេរសារណាដើម្បីបញ្ចប់ថ្នាក់ក្រោយឧត្តមសិក្សារបស់ពួកគេជាដើម។

ទោះបីជាយ៉ាងណា ផ្អែកតាមការសង្កេតរបស់អ្នកស្រាវជ្រាវ និងតាមរយៈការសាកសួរនិស្សិតក៏ដូចជាសាស្ត្រាចារ្យមួយចំនួនលើមុខវិជ្ជាសិក្សាវិធីសាស្ត្រស្រាវជ្រាវនេះ បានឱ្យដឹងថា ការសិក្សាមុខវិជ្ជានេះនៅមានចន្លោះប្រហោងច្រើនលើគុណភាពបង្រៀន ការអនុវត្តទ្រឹស្តី ក្រេឌីតសិក្សាមានរយៈពេលខ្លី ក៏ដូចជាការយល់ដឹង ចំណេះដឹង និងការយល់ឃើញរបស់ពួកគេលើជំនាញនេះ។ បញ្ហាទាំង

នោះបានបណ្តាលឱ្យសមត្ថភាពរបស់និស្សិតលើជំនាញនេះហាក់នៅមានកម្រិត ដែលជាហេតុធ្វើឱ្យពួកគេមិនចង់ធ្វើការស្រាវជ្រាវដោយខ្លួនឯង។

ដោយឈរលើមូលហេតុនេះ ការសិក្សាអំពីការយល់ដឹងមូលដ្ឋានរបស់និស្សិតថ្នាក់បរិញ្ញាបត្រលើការសិក្សាស្រាវជ្រាវពិតជាមានសារៈសំខាន់ នឹងអាចក្លាយជាលទ្ធផលសំខាន់ ដើម្បីបង្ហាញអំពីការវាស់វែងពីចំណេះដឹង និងការយល់ឃើញរបស់ពួកគេលើវិស័យនេះ ក្នុងន័យជម្រុញ និងលើកកម្ពស់គុណភាពនៃការរៀន និងបង្រៀនលើមុខវិជ្ជានេះផងដែរ។ លើសពីនេះ តាមរយៈការធ្វើសំយោគបណ្ណាល័យសាស្ត្រ (Literature Review) ស្តីអំពីការសិក្សាស្រាវជ្រាវទាក់ទងទៅនឹងការយល់ដឹងជាមូលដ្ឋាន និងការយល់ឃើញរបស់និស្សិតទៅលើការសិក្សាស្រាវជ្រាវ ជាពិសេសនៅក្នុងប្រទេសកម្ពុជា យើងបានរកឃើញថានៅមិនទាន់មាននៅឡើយទេ ហើយនេះក៏ជាកត្តាមួយទៀត ដែលធ្វើឱ្យយើងខ្ញុំដែលជាអ្នកស្រាវជ្រាវមានការចាប់អារម្មណ៍ចង់ស្វែងយល់បន្ថែមពីបញ្ហាដែលបានលើកឡើង។

## ១.២. វត្ថុបំណងស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងរួមគឺ សិក្សាអំពីការយល់ដឹងកម្រិតមូលដ្ឋានរបស់និស្សិតថ្នាក់បរិញ្ញាបត្រនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញអំពីជំនាញនៃការសិក្សាស្រាវជ្រាវ។ ការសិក្សានេះ ផ្តោតលើវត្ថុបំណងសំខាន់ៗពីរដូចខាងក្រោម៖

១. សិក្សាពីកម្រិតការយល់ដឹងមូលដ្ឋានរបស់និស្សិតថ្នាក់បរិញ្ញាបត្រអំពីចំណេះដឹងនិងជំនាញនៃការស្រាវជ្រាវ។

២. សិក្សាពីទស្សនៈរបស់និស្សិតទៅលើអត្ថប្រយោជន៍នៃការសិក្សាស្រាវជ្រាវ ក្នុងកិច្ចការរៀបចំគោលនយោបាយ ការធ្វើការសម្រេចចិត្ត និងការស្វែងរកបញ្ហាសង្គមជាដើម។

# ២. សំយោគបណ្ណាល័យសាស្ត្រ

## ២.១. តើអ្វីទៅជាការស្រាវជ្រាវ?

ការស្រាវជ្រាវគឺជាការសិក្សា ឬដំណើរការក្នុងការស្វែងរកបញ្ហានានាដោយប្រើប្រាស់វិធីសាស្ត្របែបវិទ្យាសាស្ត្រទៅតាមដំណាក់កាលនីមួយៗដោយយកចិត្តទុកដាក់បំផុត (QuestionPro, 2019)។ បើយោងទៅតាមអ្នកសង្គមវិទ្យាសញ្ជាតិអាមេរិក លោក Babbie (2007) បានកំណត់ថា "ការស្រាវជ្រាវគឺជាការស្វែងរកដែលមានលក្ខណៈជាប្រព័ន្ធ ដើម្បីបង្ហាញ ពណ៌នា ពន្យល់ សន្និដ្ឋាន ទស្សន៍ទាយ និងគ្រប់គ្រងទៅលើបាតុភូតនានាដែលកើតមានឡើងក្នុងសង្គម និងធម្មជាតិ។ ចំណុចសំខាន់មួយនៃការសិក្សាស្រាវជ្រាវគឺថា វាមានប្រើវិធីសាស្ត្រស្ថិតិសម្រាប់ការវិភាគទិន្នន័យ និងសន្និដ្ឋានលទ្ធផលនៃការស្រាវជ្រាវ។

ជាក់ស្តែង ការសិក្សាស្រាវជ្រាវគឺពុំអាចកាត់ផ្តាច់បានឡើយនូវចំណេះដឹងខាងស្ថិតិក្នុងការស្វែងរក ក៏ដូចជាបកស្រាយនូវបញ្ហាសង្គមនានា បើទោះបីជាមានវិធីសាស្ត្រស្រាវជ្រាវផ្សេងៗគ្នាទៀតដែលពុំចាំបាច់មានចំណេះនេះក៏ដោយចុះ។ នៅក្នុងយុគសម័យបច្ចុប្បន្ន អ្នកស្រាវជ្រាវត្រូវមានចំណេះដឹងទូលំទូលាយទាំងលើវិធីសាស្ត្រស្រាវជ្រាវ ស្ថិតិ ជំនាញឯកទេស ចំណេះដឹងទៅលើការសរសេរ

គម្រោងស្រាវជ្រាវ និងចំណេះដឹងក្នុងការសរសេរអត្ថបទស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រជាដើម (Owlcation, 2019; Universalclass, 2019)។

## ២.២. ចំណេះដឹងមូលដ្ឋានទាក់ទងនឹងការស្រាវជ្រាវ

បញ្ហាចម្បងមួយក្នុងការអប់រំនៅថ្នាក់ឧត្តមសិក្សាគឺ និស្សិតជាច្រើនដែលបានចូលរៀននៅថ្នាក់ឧត្តមសិក្សា ពុំមានចំណេះដឹងមូលដ្ឋានរឹងមាំគ្រប់គ្រាន់សម្រាប់ឈោងចាប់ចំណេះដឹងបែបអរូបីទៅតាមវិធីសាស្ត្ររៀន និងបង្រៀនបែបទំនើបនោះទេ។ យើងសង្កេតឃើញថា នៅក្នុងថ្នាក់ឧត្តមសិក្សា វិធីសាស្ត្រមួយដែលពេញនិយមគឺការស្រាវជ្រាវដែលមានលក្ខណៈវិទ្យាសាស្ត្រនិងស៊ីជម្រៅ ដែលជាទូទៅទាមទារឱ្យនិស្សិតសិក្សាស្វែងយល់ដោយខ្លួនឯង។ លើសពីនេះ វិធីសាស្ត្រនេះ ត្រូវបានសាស្ត្រាចារ្យតម្រូវឱ្យនិស្សិតប្រើប្រាស់ដើម្បីសរសេរកិច្ចការសាលា ឬនិក្ខេបបទបញ្ចប់ការសិក្សាជាដើម។ ដោយឡែកក្នុងប្រទេសកម្ពុជា សិស្សដែលបានបញ្ចប់ការសិក្សាពីថ្នាក់វិទ្យាល័យពុំមានបទពិសោធន៍ ឬធ្លាប់ឆ្លងកាត់ការរៀនតាមបែបនេះឡើយ ដែលជាហេតុធ្វើឱ្យពួកគេត្រូវប្រឈមនឹងបញ្ហាច្រើនក្នុងការសិក្សា។

ចំណេះដឹងមូលដ្ឋានទាក់ទងទៅនឹងវិធីសាស្ត្ររៀន ដោយប្រើប្រាស់ការស្រាវជ្រាវជាមូលដ្ឋានមានសារៈសំខាន់ក្នុងការឈោងចាប់យកចំណេះដឹងថ្មីៗ និងមានលក្ខណៈឯករាជ្យម្ចាស់ការដោយខ្លួនឯង។ ចំណេះដឹងមូលដ្ឋានក្នុងការស្រាវជ្រាវ ត្រូវបានគេចាត់ទុកថាជាជំនាញសំខាន់មួយក្នុងការសិក្សានៅថ្នាក់សាកលវិទ្យាល័យ ហើយជាទូទៅវាមានទំនាក់ទំនងខ្លាំង ដល់ការរៀនសូត្រនិងលទ្ធផលសិក្សារបស់និស្សិតក្នុងមុខវិជ្ជាផ្សេងៗ។ ដោយឡែកនៅក្នុងការស្រាវជ្រាវវិញ ចំណេះដឹងមូលដ្ឋាន បានជះឥទ្ធិពលវិជ្ជមានទាំងការទទួលបានចំណេះដឹងនិងសមត្ថភាពក្នុងការអនុវត្តជំនាញស្រាវជ្រាវ ការដោះស្រាយបញ្ហា ប្រកបដោយការវិនិច្ឆ័យខ្ពស់។ កត្តាសំខាន់មួយក្នុងការបង្កើតក្របខណ្ឌចំណេះដឹងទាក់ទងទៅនឹងការស្រាវជ្រាវ គឺការរួមបញ្ចូលគ្នាដើម្បីបង្កើតបរិយាកាសសិក្សារៀនសូត្រដែលមានន័យថា ការបង្កើតចំណេះដឹងនិងជំនាញស្រាវជ្រាវយ៉ាងសកម្មដោយផ្អែកលើចំណេះដឹងមូលដ្ឋានលើផ្នែកនេះ។

ការស្រាវជ្រាវដោយមិនមានចំណេះដឹងមូលដ្ឋានគ្រប់គ្រាន់ អាចធ្វើឱ្យលទ្ធផលនៃការស្រាវជ្រាវរបស់និស្សិតមិនស៊ីជម្រៅ ឬមិនអាចឆ្លុះបញ្ចាំងពីបញ្ហាជាក់ស្តែងដែលកើតមានឡើងក្នុងសង្គម។ ម៉្យាងវិញទៀត និស្សិតដែលមានមូលដ្ឋានចំណេះដឹងទាក់ទងទៅនឹងការស្រាវជ្រាវគ្រប់គ្រាន់ នឹងអាចមានលទ្ធភាពប្រតិបត្តិការលើកម្រិតចំណេះដឹងកម្រិតខ្ពស់ផ្សេងៗបានប្រសើរ និងមានភាពស៊ីជម្រៅ។

## ២.៣. អំពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

### ក) ទស្សនៈវិស័យនិងបេសកកម្ម

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (ស.ភ.ភ.ព) ជាសាកលវិទ្យាល័យរដ្ឋដែលមានអាយុកាលចំណាស់ និងធំជាងគេមួយនៅក្នុងប្រទេសកម្ពុជា។ បច្ចុប្បន្ន សាកលវិទ្យាល័យនេះបាននឹងកំពុងបន្តបេសកកម្មបណ្តុះបណ្តាលធនធានមនុស្សរបស់ខ្លួនយ៉ាងសកម្មលើជំនាញសិក្សាជាច្រើន ដែលសព្វថ្ងៃ

មាននិស្សិតប្រមាណជា ១២០០០នាក់កំពុងសិក្សាតាមជំនាញផ្សេងៗគ្នា ក្នុងរូបភាពអាហារូបករណ៍ និងសិក្សាបង់ថ្លៃ។

**ទស្សនៈវិស័យ**

សាកលវិទ្យាល័យភូមិន្ទភ្នំពេញនឹងអភិវឌ្ឍខ្លួនទៅជាសាកលវិទ្យាល័យលំដាប់កំពូលរបស់ជាតិ ក្នុងកិច្ចការបង្រៀន ស្រាវជ្រាវ និងបំពេញតម្រូវការសង្គម។

ដើម្បីសម្រេចបាននូវទស្សនៈវិស័យនេះ សាកលវិទ្យាល័យភូមិន្ទភ្នំពេញបានបន្តពង្រឹងគុណភាពរបស់ខ្លួនទាំងការបង្រៀន ការគ្រប់គ្រងធនធានមនុស្ស ការពង្រឹងសមត្ថភាពសាស្ត្រាចារ្យ និស្សិត និងបុគ្គលិកគ្រប់កម្រិត។ លើសពីនេះ ដើម្បីលើកកំពស់វិស័យស្រាវជ្រាវ ដែលជាមូលដ្ឋានគ្រឹះដ៏ចាំបាច់ក្នុងកិច្ចការសិក្សា ក៏ដូចជាការអភិវឌ្ឍជាតិ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានបន្តកែលម្អ និងអភិវឌ្ឍន៍កម្មវិធីសិក្សារបស់ខ្លួន ដើម្បីឱ្យស្របតាមនិយាមគុណភាពល្អ មានការប្រកួតប្រជែងខ្ពស់ ជាមួយនឹងកម្មវិធីសិក្សារបស់សាកលវិទ្យាល័យនានាក្នុងស្រុក ក្នុងតំបន់ ក៏ដូចជាពិភពលោកផងដែរ។

## ខ) មុខវិជ្ជាស្រាវជ្រាវក្នុងកម្មវិធីសិក្សានៅ ស.ភ.ភ.ព

សកលវិទ្យាល័យភូមិន្ទភ្នំពេញ (*ស.ភ.ភ.ព*) មានមហាវិទ្យាល័យនានាជាច្រើនដូចជាៈ (១) មហាវិទ្យាល័យវិទ្យាសាស្ត្រ (២) មហាវិទ្យាល័យសង្គមសាស្ត្រ និងមនុស្សសាស្ត្រ (៣) មហាវិទ្យាល័យវិស្វកម្ម (៤)មហាវិទ្យាល័យសិក្សាអភិវឌ្ឍន៍ (៥) មហាវិទ្យាល័យអប់រំ និង (៦) វិទ្យាស្ថានភាសាបរទេស។ ក្នុងនោះមហាវិទ្យាល័យនីមួយៗមានដេប៉ាតឺម៉ង់ផ្សេងៗក្រោមឱវាទសម្ព័ន្ធ (RUPP, 2019)។

បើពិនិត្យទៅលើកម្មវិធីបណ្តុះបណ្តាលនៅដេប៉ាតឺម៉ង់ទាំងអស់ ក្នុងមហាវិទ្យាល័យសង្គមសាស្ត្រ និងមនុស្សសាស្ត្រ គេឃើញមានការបញ្ចូលនូវមុខវិជ្ជាដែលពាក់ព័ន្ធជាមួយនឹងជំនាញការស្រាវជ្រាវ ដូចជាវិធីសាស្ត្រសិក្សាស្រាវជ្រាវ ស្ថិតិសម្រាប់ការស្រាវជ្រាវជាដើម។ មុខវិជ្ជាទាំងនោះភាគច្រើន ត្រូវបានដាក់បញ្ចូលនៅដើមឆ្នាំទី៣ ក្នុងឆមាសទី១សម្រាប់កម្មវិធីសិក្សាបរិញ្ញាបត្រ។ ទោះបីជាយ៉ាងណា មុខវិជ្ជាវិធីសាស្ត្រស្រាវជ្រាវនៅមហាវិទ្យាល័យនានាមាននៅចន្លោះឆ្នាំទី២ ឆមាសទី១ ដល់ឆ្នាំទី៤ ឆមាសទី១។ ការបញ្ចូលមុខវិជ្ជានេះអាចលើកកម្ពស់ការយល់ដឹងរបស់និស្សិតលើការសិក្សាស្រាវជ្រាវ ដែលជាចំណេះដឹងចាំបាច់ក្នុងការសរសេរសារណា ឬនិក្ខេបបទបញ្ចប់ការសិក្សានៅឆ្នាំទី៤។ មុខវិជ្ជាសិក្សាស្រាវជ្រាវនេះក៏ត្រូវបានបញ្ចូលឱ្យសិក្សាផងដែរសម្រាប់កម្រិតក្រោយឧត្តមសិក្សា ទាំងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត។

# ៣. វិធីសាស្ត្រស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងវត្ថុបំណងស្រាវជ្រាវទាំងពីរខាងលើ វិធីសាស្ត្រស្រាវជ្រាវបែបបរិមាណ (Quantitative Research Methodology) ត្រូវបានប្រើប្រាស់ជាគោល ដោយធ្វើការស្ទាបស្ទង់មតិ (Survey Research Method) ទៅលើក្រុមនិស្សិតគោលដៅដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

## ៣.១. សំណាកគម្រូនិងការប្រមូលទិន្នន័យ

និស្សិតដែលបានចូលរួមក្នុងការសិក្សានេះមានចំនួនសរុប១៣០នាក់ ដែលកំពុងសិក្សាថ្នាក់បរិញ្ញាបត្រតាមជំនាញផ្សេងៗក្នុងមហាវិទ្យាល័យមនុស្សសាស្ត្រនិងសង្គមសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដោយក្នុងនោះមាននិស្សិតភេទប្រុសចំនួន៥៣នាក់ និងនិស្សិតភេទស្រីចំនួន៧៧នាក់។ និស្សិតទាំងនោះត្រូវបានជ្រើសរើសតាមសំណាកចៃដន្យ (Random Sampling) ហើយត្រូវបានស្នើសុំអោយជួយបំពេញនូវកម្រងសំណួរដែលបានរៀបចំជាស្រេច។

## ៣.២. កម្រងសំណួរស្រាវជ្រាវ

កម្រងសំណួរស្រាវជ្រាវត្រូវបានរៀបចំជាទម្រង់បិទ ហើយចែកចេញជា៤ផ្នែក។ ផ្នែកទី១ មានសំណួរដែលពាក់ព័ន្ធទៅនឹងព័ត៌មានទូទៅរបស់និស្សិតដូចជា ភេទ អាយុ ជំនាញសិក្សា ស្ថានភាពនៃការសិក្សាជាដើម។ ផ្នែកទី២មានសំណួរចំនួន៨ ដែលវាស់វែងទៅលើការដែលនិស្សិតទាំងនោះធ្លាប់បានឮ ស្គាល់ ឬដឹង (Students' Awareness) ពីបញ្ញត្តិ ឬខ្លឹមសារមួយចំនួនទាក់ទងទៅនឹងការស្រាវជ្រាវ។ គ្រប់សំណួរទាំង៨នេះ ត្រូវបានវាស់វែងដោយប្រើប្រាស់ចម្លើយដែលមានស្រាប់ចំនួនបីគឺ៖ *(១) ដឹង ឮ ឬ ស្គាល់ (២) មិនដឹង* និង *(៣) មិនអាចកំណត់បាន*។ និស្សិតដែលចូលរួមក្នុងការសិក្សាទាំងអស់ តម្រូវឱ្យជ្រើសរើសនូវចម្លើយណាមួយដែលត្រូវនឹងស្ថានភាពជាក់ស្តែងរបស់ខ្លួន។ ផ្នែកទី៣ មានសំណួរចំនួន១៥ ដែលផ្តោតលើការវាយតម្លៃការយល់ដឹងមូលដ្ឋានរបស់និស្សិតទាក់ទងទៅនឹងការសិក្សាស្រាវជ្រាវ (Students' Competency in Research Skills) ហើយសំណួរទាំង១៥នេះ ត្រូវបានវាស់វែងដោយរង្វាស់លីកឃើត (Likert Scale) ដែលមាន៧កម្រិតនិងមានលេខតំណាងកម្រិតនីមួយៗដូចខាងក្រោម៖

| | | | |
|---|---|---|---|
| *០ = មិនចេះទាល់តែសោះ* | *១ = ចេះតិចតួចមែនទែន* | *២ = ចេះបន្តិចបន្តួច* | *៣ = ចេះល្មម* |
| *៤ = ចេះគួរសម* | *៥ = ចេះខ្លាំង* | *៦ = ជំនាញ* | |

សំណួរទាំង១៥នេះ មានកម្រិតជឿជាក់កម្រិតខ្ពស់ខ្លាំង (Cronbach's Alpha Item Reliability) ទំហំ 0.949។ ផ្នែកទី៤ ដែលជាផ្នែកចុងក្រោយ មានសំណួរចំនួន១៨សំណួរ ដែលក្នុងនោះ ៦សំណួរផ្តោតទៅលើទស្សនៈរបស់និស្សិតពាក់ព័ន្ធទៅនឹងបទពិសោធន៍របស់និស្សិតខ្លួនឯងទាក់ទងនឹងការសិក្សាស្រាវជ្រាវដែលមានកម្រិតជឿជាក់ (Cronbach's Alpha) ទំហំ 0.844 ដោយឡែក១២សំណួរចុងក្រោយផ្តោតទៅលើ ទស្សនៈរបស់និស្សិតអំពីការចូលរួមចំណែកឬអត្ថប្រយោជន៍នៃការស្រាវជ្រាវ ក្នុងកិច្ចការរៀបចំគោលនយោបាយ ការសម្រេចចិត្ត និងការស្វែងយល់ពីបញ្ហាសង្គមនានាជាដើម។ សំណួរទាំង១២នេះ មានកម្រិតជឿជាក់ (Cronbach's Alpha) ទំហំ 0.864។ សំណួរទាំងអស់នៅក្នុងផ្នែកទី៤នេះ ត្រូវបានវាស់វែងដោយរង្វាស់លីកឃើត (Likert Scale)ដែលមាន៥កម្រិតដែលមានលេខតំណាងដូចខាងក្រោម៖

| ទស្សនៈអវិជ្ជមាន | ទស្សនៈកណ្តាល | ទស្សនៈវិជ្ជមាន |
|---|---|---|
| *១= មិនយល់ស្របខ្លាំង* | *៣ = មិនអាចកំណត់បាន* | *៤ = យល់ស្រប* |

| | |
|---|---|
| *២= មិនយល់ស្រប* | *៥ = យល់ស្របខ្លាំង* |

## ៣.៣. ការវិភាគទិន្នន័យ

ទិន្នន័យដែលប្រមូលបាន ត្រូវបានរៀបចំនិងវិភាគដោយប្រើប្រាស់កម្មវិធី SPSS ជាគោលដែលមានវិធីវិភាគទិន្នន័យបែបពណ៌នា (Descriptive Statistics) និងការវិភាគដោយប្រើស្ថិតិសន្និដ្ឋាន (Inferential Statistics)ជាដើម។ តារាងស្ថិតិ ក្រាហ្វិកនានាត្រូវបានប្រើប្រាស់ដើម្បីពណ៌នាអំពីការយល់ដឹងមូលដ្ឋានរបស់និស្សិត និងការប្រើប្រាស់នូវតេស្តសម្មតិកម្ម (Hypothesis Testing) ដើម្បីប្រៀបធៀបពីការយល់ដឹង និងទស្សនៈរបស់និស្សិតទាក់ទងនឹងការសិក្សាស្រាវជ្រាវរវាងនិស្សិតទាំងពីរភេទ។ ចំពោះការវាយតម្លៃផ្ទាល់ខ្លួនទៅលើចំណេះដឹងទាក់ទងនឹងជំនាញការសិក្សាស្រាវជ្រាវ (Students' Competency in Research Skills) ត្រូវបានគណនាដោយយកតម្លៃមធ្យមរវាងសំណួរទាំង១៥ ហើយមានអត្ថន័យក្នុងការបកស្រាយដូចខាងក្រោម៖

| កម្រិតពិន្ទុ | ការបកស្រាយ |
|---|---|
| *០ - ២* | *ចំណេះដឹងកម្រិតទាបមិនអាចប្រើការក្នុងការស្រាវជ្រាវបាន* |
| *២ - ៣.៥* | *ចំណេះដឹងកម្រិតបង្គួរអាចប្រើប្រាស់បានក្នុងកិច្ចការស្រាវជ្រាវ* |
| *៣.៥ - ៥* | *ចំណេះដឹងកម្រិតខ្ពស់អាចប្រើប្រាស់ក្នុងការស្រាវជ្រាវដោយឯករាជ្យ* |
| *៥ - ៦* | *ចំណេះដឹងកម្រិតជំនាញអាចបប្រើប្រាស់ក្នុងការស្រាវជ្រាវបានទូលំទូលាយ* |

ចំពោះទិន្នន័យទាក់ទងនឹងការយល់ឃើញរបស់និស្សិតទាក់ទងទៅនឹងបទពិសោធ៍របស់ខ្លួនក្នុងកិច្ចការស្រាវជ្រាវ ត្រូវបានគណនាដោយយកតម្លៃមធ្យមដូចគ្នាទៅតាមចំនួនសំណួរដែលបានរៀបរាប់ខាងលើ ហើយអត្ថន័យក្នុងការបកស្រាយមានដូចខាងក្រោម៖

| កម្រិតពិន្ទុ | ការបកស្រាយ |
|---|---|
| *១ - ២.៥* | *បានចូលរួមនិងមានបទពិសោធន៍តិចតួចក្នុងកិច្ចការស្រាវជ្រាវ* |
| *២.៥ - ៣.៥* | *បានចូលរួមនិងមានបទពិសោធន៍ច្រើនគួរសមក្នុងកិច្ចការស្រាវជ្រាវ* |
| *៣.៥ - ៥* | *បានចូលរួមនិងមានបទពិសោធន៍ច្រើនក្នុងកិច្ចការស្រាវជ្រាវ* |

ចំពោះទិន្នន័យដែលពាក់ព័ន្ធនឹងទស្សនៈរបស់និស្សិតទៅលើ អត្ថប្រយោជន៍នៃការសិក្សាស្រាវជ្រាវក្នុងកិច្ចការដូចជា ការរៀបចំគោលនយោបាយ ការសម្រេចចិត្តនិងរកបញ្ហាសង្គមជាដើម មានអត្ថន័យក្នុងការបកស្រាយមានដូចខាងក្រោម៖

| កម្រិតពិន្ទុ | ការបកស្រាយ |
|---|---|
| *១ - ២.៥* | *ការសិក្សាស្រាវជ្រាវមានអត្ថប្រយោជន៍តិចតួចក្នុងកិច្ចការងារដូចជា ការរៀបចំគោលនយោបាយ ការសម្រេចចិត្ត និងរកបញ្ហាសង្គមនានា* |
| *២.៥ - ៣.៥* | *ការសិក្សាស្រាវជ្រាវមានអត្ថប្រយោជន៍ច្រើនគួរសមក្នុងកិច្ចការងារដូចជា ការរៀបចំគោលនយោបាយ ការសម្រេចចិត្ត និងរកបញ្ហាសង្គមនានា* |

### *៣.៥ - ៥ ការសិក្សាស្រាវជ្រាវមានអត្ថប្រយោជន៍ខ្លាំងនិងចូលរួមយ៉ាងសស្រាក់សស្រាំក្នុងកិច្ចការងារដូចជា ការរៀបចំគោលនយោបាយ ការសម្រេចចិត្ត និងរកបញ្ហាសង្គមនានា*

លទ្ធផលនៃការស្វែងយល់ពីទិន្នន័យ (Data Exploratory Analysis) ដោយប្រើ Q-Q Plot និងការធ្វើតេស្តរបាយទិន្នន័យដោយប្រើ Shapiro-Wilk Normality Test បង្ហាញថា របាយទិន្នន័យចំណេះដឹងទាក់ទងនឹងជំនាញការសិក្សាស្រាវជ្រាវ (Students' Competency in Research Skills) របស់និស្សិតមានលក្ខណៈមិនណរម៉ាល់ (Non Normal Distribution) នេះបើតាមលទ្ធផល Shapiro-Wilk Normality Test (Sig. 000 at 99.99%)។

**របាយទិន្នន័យតាមរយៈNormal Q-Q Plot**




ដូចគ្នាដែរ តាម Normal Q-Q Plot និងលទ្ធផលរបស់ Shapiro-Wilk Normality Tests ក្នុងការពិនិត្យទៅលើរបាយទិន្នន័យ នៃការយល់ឃើញរបស់និស្សិតទាក់ទងទៅនឹងបទពិសោធ៍របស់ខ្លួនក្នុងកិច្ចការស្រាវជ្រាវ (Students' Experience & Engagement in Research) ព្រមទាំងទស្សនៈរបស់គេទៅលើអត្ថប្រយោជន៍នៃការសិក្សាស្រាវជ្រាវ (Perception about Research's Contribution) ក្នុងកិច្ចការដូចជា ការរៀបចំគោលនយោបាយ ការសម្រេចចិត្ត និងការរកបញ្ហាសង្គមជាដើម បានបង្ហាញថារបាយទិន្នន័យទាំងពីរនេះមានលក្ខណៈមិនណរម៉ាល់ដូចគ្នា (Sig. 0.003 និង Sig. 0.000 រៀងគ្នា)។

តាមលទ្ធផលទាំងនេះ តេស្តស្ថិតិ Independent Samples Mann-Whitney U Test នឹងត្រូវប្រើប្រាស់ដើម្បីធ្វើការប្រៀបធៀបពី ចំណេះដឹងមូលដ្ឋានទាក់ទងនឹងការស្រាវជ្រាវ ការវាយតម្លៃ

ផ្ទាល់ខ្លួនទៅលើបទពិសោធន៍លើការស្រាវជ្រាវ និងទស្សនៈទាក់ទងនឹងអត្ថប្រយោជន៍នៃការស្រាវជ្រាវ របស់និស្សិតទាំងពីរភេទ។

## ៣.៤. ដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ដោយសារការសិក្សានេះមានលក្ខណៈជាករណីសិក្សាតូចមួយពាក់ព័ន្ធទៅនឹងបញ្ហាដែលបានលើកឡើងក្នុងចំណោទបញ្ហា *(ចំណុច១.១)* ខាងលើ ដូចនេះ ការសិក្សាស្រាវជ្រាវមួយនេះ មានដែនកំណត់ដូចខាងក្រោម៖

១) ការស្រាវជ្រាវទៅលើចំណេះដឹងមូលដ្ឋាន របស់និស្សិតដែលបានចូលរួមក្នុងការសិក្សានេះមិនបានឆ្លុះបញ្ចាំងពីទូទៅភាពរបស់និស្សិតដែលកំពុងសិក្សាក្នុងសាកលវិទ្យាល័យភូមិន្ទភ្នំពេញនោះទេ ដោយហេតុថាសំណាកគម្រូនៃការសិក្សានេះមានចំនួនតិច ត្រឹមតែ១៣០នាក់។

២) ដោយសារតែនិស្សិតដែលបានចូលរួមក្នុងការសិក្សាទាំងអស់ មានជំនាញខាងវិទ្យាសាស្ត្រសង្គម ដូចនេះចំណេះដឹងមូលដ្ឋាននិងទស្សនៈរបស់គាត់ពុំបានឆ្លុះបញ្ចាំងទាំងស្រុងដល់ស្ថានភាពជាក់ស្តែងរបស់និស្សិតដែលកំពុងសិក្សាលើជំនាញវិទ្យាសាស្ត្រពិតនោះទេ។

៣) លទ្ធផលនៃការសិក្សាទាក់ទងនឹងចំណេះដឹងមូលដ្ឋាននេះ ពុំបានធ្វើការវាស់វែងចំណេះដឹងតាមរយៈការធ្វើតេស្តចំណេះដឹងជាក់ស្តែងនោះទេ តែគ្រាន់តែឱ្យនិស្សិតដែលចូលរួមធ្វើការវាយតម្លៃកម្រិតចំណេះដឹងរបស់ខ្លួនទៅតាមស្ថានភាពជាក់ស្តែងរបស់ពួកគេ។ ដូចនេះចំណេះដឹងជាក់ស្តែងរបស់និស្សិត (បើឆ្លងកាត់ការធ្វើតេស្តចំណេះដឹង) អាចនឹងមានភាពប្រែប្រួលខ្លះៗពីអ្វីដែលបានបង្ហាញនៅក្នុងលទ្ធផលនៃការសិក្សាមួយនេះ។

# ៤. លទ្ធផលនិងការពិភាក្សា

## ៤.១. ព័ត៌មានទូទៅរបស់និស្សិត

លទ្ធផលស្រាវជ្រាវបានបង្ហាញថា ក្នុងចំណោមនិស្សិតទាំង១៣០នាក់ ដែលបានចូលរួមក្នុងការសិក្សាមាននិស្សិតជាប្រុសចំនួន៥៣នាក់ និងនិស្សិតស្រីចំនួន ៧៧នាក់ ដែលមានអាយុភាគច្រើនក្នុងចន្លោះពី ១៨ ទៅ២៣ឆ្នាំ។

តារាងទី១៖ ក្រុមអាយុរបស់និស្សិតទៅតាមភេទទាំងពីរ

| | | អាយុ | | | *សរុប* |
|---|---|---|---|---|---|
| | | 18-23 | 24-30 | 31-40 | |
| ភេទ | ប្រុស | 49 | 4 | 0 | *53* |
| | ស្រី | 76 | 0 | 1 | *77* |
| | *សរុប* | *125* | *4* | *1* | *130* |

ក្នុងចំណោមនិស្សិតទាំងនោះ មាននិស្សិតប្រមាណជា ៣៧% ដែលគ្មានការងារធ្វើ ដែលក្រៅពីនោះ ពួកគេមានការងារក្រៅម៉ោង (២០%) ការងារពេញម៉ោង (៣៧.៧%) និង ៣.៨% ផ្សេងទៀតមានមុខរបរផ្ទាល់ខ្លួន។

តារាងទី២៖ ព័ត៌មានទាក់ទងនឹងស្ថានភាពនៃការសិក្សារបស់និស្សិត

| | ចំនួន | ភាគរយ | ភាគរយបានការ |
|---|---|---|---|
| និស្សិតមានការងារក្រៅម៉ោង | 26 | 20.0 | 20.3 |
| និស្សិតមានការងារពេញម៉ោង | 49 | 37.7 | 38.3 |
| និស្សិតមានមុខរបរផ្ទាល់ខ្លួន | 5 | 3.8 | 3.9 |
| និស្សិតគ្មានមុខរបរឬការងារ | 48 | 36.9 | 37.5 |
| *សរុប* | *128* | *98.5* | *100.0* |
| ទិន្នន័យបាត់បង់ | 2 | 1.5 | |
| សរុប | 130 | 100.0 | |

បើពិនិត្យមើលលម្អិតទៅលើស្ថានភាពការងាររបស់និស្សិតទាំងនោះ ឃើញថា មាននិស្សិតលើសពី ២៧% ដែលមានការងារធ្វើពាក់ព័ន្ធទៅនឹងការស្រាវជ្រាវ។

តារាងទី៣៖ ស្ថានភាពនិស្សិតទាក់ទងជាមួយនឹងការងារ

| | ចំនួន/ប្រេកង់ | ភាគរយ | ភាគរយបានការ | ប្រេកង់កើន |
|---|---|---|---|---|
| និស្សិតគ្មានការងារ | 48 | 36.9 | 39.3 | 39.3 |
| ការងារកម្រិតទាបមិនពាក់ព័ន្ធនឹងការស្រាវជ្រាវ | 23 | 17.7 | 18.9 | 58.2 |
| ការងារកម្រិតទាបពាក់ព័ន្ធនឹងការស្រាវជ្រាវ | 14 | ***10.8*** | 11.5 | 69.7 |
| ការងារកម្រិតកណ្ដាលមិនពាក់ព័ន្ធនឹងការស្រាវជ្រាវ | 12 | 9.2 | 9.8 | 79.5 |
| ការងារកម្រិតកណ្ដាលពាក់ព័ន្ធនឹងការស្រាវជ្រាវ | 17 | ***13.1*** | 13.9 | 93.4 |
| ការងារកម្រិតខ្ពស់មិនពាក់ព័ន្ធនឹងការស្រាវជ្រាវ | 3 | 2.3 | 2.5 | 95.9 |
| ការងារកម្រិតខ្ពស់ពាក់ព័ន្ធនឹងការស្រាវជ្រាវ | 5 | ***3.8*** | 4.1 | 100.0 |
| *សរុប* | *122* | *93.8* | *100.0* | |

| | | |
|---|---|---|
| ទិន្នន័យបាត់បង់ | 8 | 6.2 |
| *សរុប* | *130* | *100.0* |

## ៤.២. កម្រិតនៃការយល់ដឹងអំពីការសិក្សាស្រាវជ្រាវ

លទ្ធផលនៃការស្រាវជ្រាវបានបង្ហាញថា និស្សិតថ្នាក់បរិញ្ញាបត្រនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញដែលបានចូលរួមក្នុងការសិក្សានេះ មានចំណេះដឹងមូលដ្ឋានលើការសិក្សាស្រាវជ្រាវនៅមានកម្រិតនៅឡើយ។

តារាងទី៤៖ ភាគរយនិស្សិតដែលឆ្លើយថាបានដឹង ឮ ឬ ស្គាល់បញ្ញត្តទាក់ទងនឹងការស្រាវជ្រាវ និងការបោះពុម្ពអត្ថបទវិទ្យាសាស្ត្រ (N=130)

| សំណួរ | ដឹង ឮ ឬ ស្គាល់ | មិនដឹង | មិនអាចកំណត់បាន | សរុប |
|---|---|---|---|---|
| តើអ្នកធ្លាប់ដឹង ឮ ឬស្គាល់ បញ្ញត្តផ្សេងៗ ទាក់ទងនឹងការស្រាវជ្រាវដូចជា វិធីសាស្ត្រស្រាវជ្រាវ ការបោះពុម្ពអត្ថបទវិទ្យាសាស្ត្រដែរឬទេ? (សំណួរ១) | *61.2* | 17.1 | 21.7 | 100.0 |
| តើអ្នកធ្លាប់ដឹង ឮ ឬស្គាល់ បញ្ញត្តផ្សេងៗ ទាក់ទងនឹងស្ថិតិដូចជា តេស្តស្ថិតិ, t-Test, ANOVA or Chi-Square, Regression …ដែរឬទេ? (សំណួរ២) | 22.3 | *49.2* | 28.5 | 100.0 |
| តើអ្នកធ្លាប់ដឹង ឮ ឬស្គាល់ ប្រភេទនៃស្ថិតិ (Type of Statistic) ដូចជា ស្ថិតិពណ៌នា (Descriptive Statistics) ស្ថិតិសន្និដ្ឋាន (Inferential Statistics) ដែរឬទេ? (សំណួរ៣) | *47.6* | 26.2 | 26.2 | 100.0 |
| តើអ្នកធ្លាប់ដឹង ឮ ឬស្គាល់ ប្រភេទផ្សេងៗនៃការស្រាវជ្រាវដូចជា ការស្រាវជ្រាវបែបពិសោធន៍ (Experimental Research) ការស្រាវជ្រាវបែប Cross-sectional ឬ ការស្រាវជ្រាវបែបស្ទង់មតិ (Survey) … ដែរឬទេ? (សំណួរ៤) | *53.1* | 25.4 | 21.5 | 100.0 |

| | | | | |
|---|---|---|---|---|
| តើអ្នកធ្លាប់ដឹង ឮ ឬស្គាល់ បញ្ញត្តផ្សេងៗ ដូចជា Citation និង Referencing ... ដែរឬទេ? (សំណួរ៥) | *46.4* | *34.4* | 19.2 | 100.0 |
| តើអ្នកធ្លាប់ដឹង ឮ ឬស្គាល់ បញ្ញត្តផ្សេងៗ ដូចជាអថេរឬអញ្ញតិ (Variable) ឬ Level of Measurement ...ដែរឬទេ? (សំណួរ៦) | *35.2* | *38.3* | 26.5 | 100.0 |
| តើអ្នកធ្លាប់ដឹង ឮ ឬស្គាល់ បញ្ញត្តផ្សេងៗ ដូចជាការវិភាគទិន្នន័យ (Data Analysis) ការបង្ហាញព័ត៌មានជារូបភាព (Data Visualization) ការសម្អាតទិន្នន័យ (Data Cleaning ) និងការបញ្ចូលទិន្នន័យដែរឬទេ? (សំណួរ៧) | *49.2* | 20.8 | 30.0 | 100.0 |
| តើអ្នកធ្លាប់ដឹង ឮ ឬស្គាល់ បញ្ញត្តផ្សេងៗ ដូចជា បញ្ហាស្រាវជ្រាវ (Research Problem) សំណួរស្រាវជ្រាវ (Research Question) ការធ្វើតេស្តសម្មតិកម្មដែរឬទេ? (សំណួរ៨) | *55.4* | 21.5 | 23.1 | 100.0 |

តាមតារាងខាងលើ និស្សិតដែលបានចូលរួមក្នុងការសិក្សានេះ ធ្លាប់បានដឹង ឮ ឬស្គាល់ ខ្លឹមសារឬបញ្ញត្តិទាក់ទងនឹងវិធីសាស្ត្រស្រាវជ្រាវ ច្រើនជាង ខ្លឹមសារឬបញ្ញត្តិនានាទាក់ទងទៅនឹងស្ថិតិនិងការវិភាគទិន្នន័យ (ភាគរយនិស្សិតដែលឆ្លើយថាធ្លាប់ដឹងលើគ្រប់សំណួរទាក់ទងនឹងស្ថិតិមានមិនលើសពី ៥០% ដោយឡែកភាគរយនៃអ្នកឆ្លើយថាធ្លាប់ដឹងលើសំណួរទាក់ទងនឹងវិធីសាស្ត្រស្រាវជ្រាវមានលើសពី៥០%)។ លទ្ធផលនេះក៏អាចឆ្លុះបញ្ចាំងផងដែរពីចំណេះដឹងដែលនិស្សិតទទួលបានពីការសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ តាមតារាងទី៥ខាងក្រោម លទ្ធផលបង្ហាញថា ភាគច្រើននៃនិស្សិតដែលបានឆ្លើយថា ធ្លាប់បានដឹង ឮ ឬស្គាល់ ខ្លឹមសារឬបញ្ញត្តិនៃសំណួរនីមួយៗទាក់ទងនឹងការស្រាវជ្រាវ ភាគច្រើនជានិស្សិតដែលមិនទាន់មានការងារ។ ទាំងនេះ អាចដោយសារតែនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានដាក់មុខវិជ្ជាទាក់ទងទៅនឹងវិធីសាស្ត្រស្រាវជ្រាវនៅក្នុងកម្មវិធីសិក្សាសម្រាប់ថ្នាក់បរិញ្ញាបត្រក្នុងមុខជំនាញវិទ្យាសាស្ត្រសង្គមនានា។

តារាងទី៥៖ ការធ្លាប់បានដឹង ឮ ឬស្គាល់ ខ្លឹមសារឬបញ្ញត្តិទាក់ទងនឹងវិធីសាស្ត្រស្រាវជ្រាវ ទៅតាមស្ថានភាពការងារ

| | សូមពិនិត្យមើលអត្ថន័យនៃសំណួរនីមួយៗក្នុងតារាងទី៣ខាងលើ | | | | | | | |
|---|---|---|---|---|---|---|---|---|
| | (សំណួរទី១) | (សំណួរទី២) | (សំណួរទី៣) | (សំណួរទី៤) | (សំណួរទី៥) | (សំណួរទី៦) | (សំណួរទី៧) | (សំណួរទី៨) |
| និស្សិតមិនទាន់មានការងារ | *31* | *11* | *17* | *21* | *14* | *10* | *16* | *26* |
| ការងារកម្រិតទាបមិនពាក់ព័ន្ធនឹងការស្រាវជ្រាវ | 14 | 5 | 12 | 13 | 10 | 12 | 9 | 11 |
| ការងារកម្រិតទាបពាក់ព័ន្ធនឹងការស្រាវជ្រាវ | *11* | *4* | *5* | *6* | *6* | *3* | *9* | *9* |
| ការងារកម្រិតកណ្តាលមិនពាក់ព័ន្ធនឹងការស្រាវជ្រាវ | 7 | 1 | 6 | 7 | 7 | 4 | 7 | 8 |
| ការងារកម្រិតកណ្តាលពាក់ព័ន្ធនឹងការស្រាវជ្រាវ | *11* | *5* | *12* | *10* | *10* | *9* | *13* | *11* |
| ការងារកម្រិតខ្ពស់មិនពាក់ព័ន្ធនឹងការស្រាវជ្រាវ | 1 | 1 | 2 | 2 | 3 | 2 | 1 | 2 |
| ការងារកម្រិតខ្ពស់ពាក់ព័ន្ធនឹងការស្រាវជ្រាវ | 0 | 1 | 4 | 4 | 5 | 3 | 4 | 2 |

ទោះជាយ៉ាងណា យើងក៏អាចទាញបានផងដែរថា ការយល់ដឹងកម្រិតដំបូងរបស់និស្សិតទាំងនោះ ក៏ដោយសារតែពួកគេបានប្រឡូកក្នុងកិច្ចការងារដែលមានការទទួលខុសត្រូវលើការស្រាវជ្រាវកម្រិតណាមួយក៏ថាបាន។ បើយើងពិនិត្យទៅលើស្ថានភាពការងាររបស់និស្សិត យើងឃើញថាមាននិស្សិតច្រើនជាង***២៧%*** ដែលមានការងារធ្វើពាក់ព័ន្ធនឹងការស្រាវជ្រាវ (តារាងទី៣) និងមាននិស្សិតមួយចំនួនដែលមានការងារធ្វើពាក់ព័ន្ធនឹងការស្រាវជ្រាវ បានឆ្លើយថាខ្លួន ធ្លាប់បានដឹង ឮ ឬស្គាល់ ខ្លឹមសារឬបញ្ញត្តិទាក់ទងសំណួរនីមួយៗស្រាវជ្រាវ។

ដោយឡែក បើយើងពិនិត្យមើលទៅលើលទ្ធផលនៃការវាយតម្លៃចំណេះដឹងមូលដ្ឋានរបស់និស្សិតទាក់ទងទៅនឹងជំនាញក្នុងការស្រាវជ្រាវវិញ (Students' Competency in Research Skills) ឃើញថាមានកម្រិតទាបខ្លាំងនិងមិនអាចយកទៅប្រើប្រាស់បានក្នុងកិច្ចការស្រាវជ្រាវនោះទេ (តម្លៃមធ្យមក្នុងការវាស់វែងជំនាញទាក់ទងនឹងការស្រាវជ្រាវដោយប្រើ Likert Scale គឺត្រឹមកម្រិត $\bar{X}$=1.7868)។

| កម្រិតពិន្ទុ | ការបកស្រាយ |
|---|---|
| *០ - ២* | *ចំណេះដឹងកម្រិតទាបមិនអាចប្រើការក្នុងការស្រាវជ្រាវបាន* |
| *២ - ៣.៥* | *ចំណេះដឹងកម្រិតបង្គួរអាចប្រើប្រាស់បានក្នុងកិច្ចការស្រាវជ្រាវ* |

| | |
|---|---|
| *៣.៥ - ៥* | *ចំណេះដឹងកម្រិតខ្ពស់អាចប្រើប្រាស់ក្នុងការស្រាវជ្រាវដោយឯករាជ្យ* |
| *៥ - ៦* | *ចំណេះដឹងកម្រិតជំនាញអាចបប្រើប្រាស់ក្នុងការស្រាវជ្រាវបានទូលំទូលាយ* |

ម្យ៉ាងទៀត លទ្ធផលនៃការវិភាគដោយប្រើ Independent Samples Mann-Whitney U Test បង្ហាញថានិស្សិតប្រុស និងនិស្សិតស្រី មានចំណេះដឹងមូលដ្ឋានទាក់ទងនឹងជំនាញស្រាវជ្រាវប្រហាក់ប្រហែលគ្នា (U=1831.5, $N_1$=53, $N_2$=77, p=.322, two-tailed និង Mean Rank នៃភេទទាំងពីរ)។

តារាងទី៦៖ លំដាប់ថ្នាក់តម្លៃមធ្យមនៃការវាយតម្លៃចំណេះដឹងមូលដ្ឋានរបស់និស្សិតទាក់ទងទៅនឹងការស្រាវជ្រាវទៅតាមភេទ

| | ភេទ | ចំនួន | លំដាប់ថ្នាក់តម្លៃមធ្យម | ផលបូកលំដាប់ថ្នាក់ |
|---|---|---|---|---|
| ចំណេះដឹងទាក់ទងនឹងជំនាញការសិក្សាស្រាវជ្រាវ (Students′ Competency in Research Skills) | ប្រុស | 53 | 69.44 | 3680.50 |
| | ស្រី | 77 | 62.79 | 4834.50 |
| | សរុប | 130 | | |

ផ្ទុយមកវិញ បើទោះបីជាចំណេះដឹងមូលដ្ឋានទាក់ទងនឹងការស្រាវជ្រាវរបស់និស្សិតទាំងនេះនៅមានកម្រិតទាប ក៏ប៉ុន្តែ ពួកគេបានចូលរួមក្នុងកិច្ចការស្រាវជ្រាវបានក្នុងកម្រិតមួយគួរឱ្យកត់សម្គាល់ (តម្លៃមធ្យមក្នុងការវាស់វែងការចូលរួមក្នុងការស្រាវជ្រាវដោយប្រើ Likert Scale គឺ $\bar{X}$=2.6292)។

| កម្រិតពិន្ទុ | ការបកស្រាយ |
|---|---|
| *១ - ២.៥* | *បានចូលរួមនិងមានបទពិសោធន៍តិចតួចក្នុងកិច្ចការស្រាវជ្រាវ* |
| *២.៥ - ៣.៥* | *បានចូលរួមនិងមានបទពិសោធន៍ច្រើនគួរសមក្នុងកិច្ចការស្រាវជ្រាវ* |
| *៣.៥ - ៥* | *បានចូលរួមនិងមានបទពិសោធន៍ច្រើនក្នុងកិច្ចការស្រាវជ្រាវ* |

ដូចគ្នាដែរ លទ្ធផលនៃ Independent Samples Mann-Whitney U Test បង្ហាញថានិស្សិតទាំងពីរភេទ មានការចូលរួមរបស់និស្សិតក្នុងកិច្ចការស្រាវជ្រាវប្រហាក់ប្រហែលគ្នា (U=1968.0, $N_1$=53, $N_2$=77, p=.731, two-tailed និង Mean Rank នៃភេទទាំងពីរ)។

តារាងទី៧៖ តារាងលំដាប់ថ្នាក់តម្លៃមធ្យមនៃការចូលរួមរបស់និស្សិតក្នុងការស្រាវជ្រាវទៅតាមភេទ

| | ភេទ | ចំនួន | លំដាប់ថ្នាក់តម្លៃមធ្យម | ផលបូកលំដាប់ថ្នាក់ |
|---|---|---|---|---|
| ការចូលរួមរបស់និស្សិតក្នុងការស្រាវជ្រាវ (Students′ Engagement in Research) | ប្រុស | 53 | 66.87 | 3544.00 |
| | ស្រី | 77 | 64.56 | 4971.00 |
| | *សរុប* | *130* | | |

ដោយឡែកបើយើងពិនិត្យទៅលើលទ្ធផលនៃការវិភាគ ពីទំនាក់ទំនងរវាងការចូលរួមនិងបទពិសោធន៍និស្សិតក្នុងកិច្ចការស្រាវជ្រាវ ជាមួយនឹងចំណេះដឹងមូលដ្ឋានរបស់និស្សិតទាក់ទងនឹងការស្រាវជ្រាវវិញ ឃើញថាមានកម្រិតទាប ដោយលទ្ធផលនៃមេគុណទំនាក់ទំនងមានត្រឹមកម្រិត r=.284** ប៉ុណ្ណោះ។ ដូចគ្នាដែរ បើយើងពិនិត្យទៅលើក្រាហ្វិករបាយទំនាក់ទំនងនៃអថេរទាំងពីរនេះវិញ វាសឹងតែមិនបង្ហាញពីទំនាក់ទំនងទាល់តែសោះ។ ជាមួយនឹងលទ្ធផលនេះ យើងមិនអាចសន្និដ្ឋានបានទាំងស្រុងនោះទេថា ចំណេះដឹងមូលដ្ឋានរបស់និស្សិត ទាក់ទងនឹងការស្រាវជ្រាវដែលពួកគេមាន គឺបានមកពីបទពិសោធន៍ទាក់ទងនឹងការស្រាវជ្រាវដែលពួកគេធ្លាប់បានឆ្លងកាត់។ លទ្ធផលនេះគឺមានភាពស្រដៀងគ្នានឹងលទ្ធផលការស្រាវជ្រាវរបស់លោក Gunuc (2014) ដែលបានបញ្ជាក់ថា ការចូលរួមរបស់និស្សិតក្នុងគ្រប់រូបភាពនៃសកម្មភាពសិក្សា បានចូលរួមចំណែកក្នុងលទ្ធផលនៃការសិក្សារបស់ពួកគេបានត្រឹមតែ ១០%ប៉ុណ្ណោះ។ ទោះបីជាយ៉ាងណា លទ្ធផលស្រាវជ្រាវរបស់ Lei, Cui and Zhou (2018) បានបង្ហាញថា ការចូលរួមរបស់និស្សិតក្នុងគ្រប់សកម្មភាពសិក្សា មានទំនាក់ទំនងកម្រិតបង្គួរជាមួយនឹងលទ្ធផលនៃការសិក្សារបស់ពួកគេ។




## ៤.៣. ទស្សនៈនិស្សិតលើការសិក្សាស្រាវជ្រាវ

ដូចដែលបានបញ្ជាក់ក្នុងចំណុច ៣.៣ ខាងលើ ទស្សនៈក្នុងការវាយតម្លៃរបស់និស្សិតទាក់ទងទៅនឹងអត្ថប្រយោជន៍ និងការរួមចំណែករបស់ការស្រាវជ្រាវក្នុងកិច្ចការរៀបចំគោលនយោបាយ ការសម្រេចចិត្ត ក៏ដូចជាការស្វែងរកបញ្ហាសង្គមជាដើមត្រូវបានគណនាជាតម្លៃមធ្យម។ ជាលទ្ធផល ការស្រាវជ្រាវនេះបង្ហាញថា និស្សិតថ្នាក់បរិញ្ញាបត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញបានឱ្យតម្លៃខ្ពស់អំពីអត្ថប្រយោជន៍នៃការស្រាវជ្រាវក្នុងកិច្ចការធ្វើគោលនយោបាយ ការសម្រេចចិត្ត និងការស្វែងរកបញ្ហាសង្គម (តម្លៃមធ្យមក្នុងការវាស់វែងអត្ថប្រយោជន៍នៃការស្រាវជ្រាវដោយប្រើ Likert Scale គឺ $\bar{X}$=3.5280)។

| កម្រិតពិន្ទុ | ការបកស្រាយ |
|---|---|

| | |
|---|---|
| *១ - ២.៥* | *ការសិក្សាស្រាវជ្រាវមានអត្ថប្រយោជន៍តិចតួចក្នុងកិច្ចការងារដូចជា ការរៀបចំគោលនយោបាយ ការសម្រេចចិត្ត និងរកបញ្ហាសង្គមនានា* |
| *២.៥ - ៣.៥* | *ការសិក្សាស្រាវជ្រាវមានអត្ថប្រយោជន៍ច្រើនគួរសមក្នុងកិច្ចការងារដូចជា ការរៀបចំគោលនយោបាយ ការសម្រេចចិត្ត និងរកបញ្ហាសង្គមនានា* |
| *៣.៥ - ៥* | *ការសិក្សាស្រាវជ្រាវមានអត្ថប្រយោជន៍ខ្លាំងនិងចូលរួមយ៉ាងសស្រាក់សស្រាំក្នុងកិច្ចការងារដូចជា ការរៀបចំគោលនយោបាយ ការសម្រេចចិត្ត និងរកបញ្ហាសង្គមនានា* |

បើពិនិត្យទៅលើលទ្ធផលនៃការវិភាគដោយប្រើ Independent Samples Mann-Whitney U Test បង្ហាញថានិស្សិតទាំងពីរភេទមានទស្សនៈប្រហាក់ប្រហែលគ្នា (U=1936.5, $N_1$=53, $N_2$=77, p=.622, two-tailed និង Mean Rank នៃភេទទាំងពីរ)។ ជាមួយនឹងគ្រប់ចំណុចទាំងអស់ដែលនិស្សិតបានធ្វើការវាយតម្លៃ យើងសង្កេតឃើញថា ពួកគេបានវាយតម្លៃខ្ពស់ជាងគេ (តម្លៃមធ្យម = 3.96) ទៅលើចំណុចដែលថា "ការស្រាវជ្រាវគឺជាមធ្យោបាយសម្រាប់ការបង្កើតចំណេះដឹង និងវិធីសាស្ត្ររៀនដ៏មានប្រសិទ្ធិភាព" ដោយឡែក ចំណុចដែលពួកគេបានវាយតម្លៃទាបជាងគេនោះគឺ "អ្នកស្រាវជ្រាវទទួលបានប្រាក់បៀវត្ស និងអត្ថប្រយោជន៍ប្រសើរជាងគេ (តម្លៃមធ្យម =3.05)"។

តារាងទី៨៖ តារាងលំដាប់ថ្នាក់តម្លៃមធ្យមនៃការវាយតម្លៃលើអត្ថប្រយោជន៍ការស្រាវជ្រាវទៅតាមភេទ

| | ភេទ | ចំនួន | លំដាប់ថ្នាក់តម្លៃមធ្យម | ផលបូកលំដាប់ថ្នាក់ |
|---|---|---|---|---|
| អត្ថប្រយោជន៍នៃការស្រាវជ្រាវក្នុងកិច្ចការធ្វើគោលនយោបាយ ការសម្រេចចិត្ត និងការស្វែងរកបញ្ហាសង្គម (Perception about Research's Contribution) | ប្រុស | 53 | 67.46 | 3575.50 |
| | ស្រី | 77 | 64.15 | 4939.50 |
| | *សរុប* | *130* | | |

បើពិនិត្យទៅលើទំនាក់ទំនងរវាង ចំណេះដឹងមូលដ្ឋានទាក់ទងនឹងការស្រាវជ្រាវ ការចូលរួមឬបទពិសោធន៍ទាក់ទងនឹងការស្រាវជ្រាវ ជាមួយនឹងទស្សនៈរបស់ពួកគេទាក់ទងនឹងអត្ថប្រយោជន៍នៃការស្រាវជ្រាវ យើងឃើញថា ទំនាក់ទំនងនេះមានកម្រិតតិចតួចបំផុត (មើលតារាងមេគុណទំនាក់ទំនងខាងក្រោម)។

តារាងទី៩៖ Pearson's Correlation Matrix & P-Value

| | ចំណេះដឹងរបស់និស្សិតទាក់ទងនឹងការស្រាវជ្រាវ | ការចូលរួមឬបទពិសោធន៍ទាក់ទងនឹងការស្រាវជ្រាវ |
|---|---|---|

| | | |
|---|---|---|
| ទស្សនៈនិស្សិតទាក់ទងនឹងអត្ថប្រយោជន៍របស់ការស្រាវជ្រាវ | .216* | .312** |

**. Correlation is significant at the 0.01 level (2-tailed).

*. Correlation is significant at the 0.05 level (2-tailed).




## ៥. សេចក្តីសន្និដ្ឋាននិងអនុសាសន៍

លទ្ធផលនៃការសិក្សានេះបានបង្ហាញថា និស្សិតថ្នាក់បរិញ្ញាបត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មានកម្រិតចំណេះដឹងមូលដ្ឋានទាក់ទងនឹងការស្រាវជ្រាវមានកំណត់ ដែលចំណេះដឹងកម្រិតនេះ ពុំអាចជួយពួកគេធ្វើការស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រដោយឯករាជ្យបាននៅឡើយទេ។ លទ្ធផលក៏បានបង្ហាញថា ចំណេះដឹងមូលដ្ឋានទាក់ទងនឹងការស្រាវជ្រាវរបស់គេ គ្មានភាពខុសប្លែកគ្នាទៅតាមភេទនោះទេ។ មូលហេតុមួយដែលពួកគេមានចំណេះដឹងទាបអាចដោយសារតែការចូលរួមរបស់គេក្នុងកិច្ចការស្រាវជ្រាវ ឬមានបទពិសោធន៍តិចតួចក្នុងកិច្ចការទាំងនេះ (ទំនាក់ទំនងត្រឹមកម្រិត r=.284)។ ទោះបីជាចំណេះដឹងមូលដ្ឋានរបស់គេមានកម្រិតទាប ក៏ប៉ុន្តែ ពួកគេបានឱ្យតម្លៃខ្ពស់ទៅលើការស្រាវជ្រាវក្នុងការស្វែងរកចំណេះដឹងថ្មីៗ ការចូលរួមក្នុងកិច្ចការរៀបចំគោលនយោបាយ ការសម្រេចចិត្ត និងការស្វែងរកបញ្ហាសង្គមជាដើម។ ទោះជាយ៉ាងណា លទ្ធផលបង្ហាញថា មានទំនាក់ទំនងតិចតួចរវាង ចំណេះដឹងមូលដ្ឋានទាក់ទងនឹងការស្រាវជ្រាវ ការចូលរួមឬបទពិសោធន៍ទាក់ទងនឹងការស្រាវជ្រាវ ជាមួយនឹងទស្សនៈនៃការវាយតម្លៃពីអត្ថប្រយោជន៍នៃការស្រាវជ្រាវ របស់ពួកគេ។

ផ្អែកទៅលើលទ្ធផល និងដែនកំណត់នៃការសិក្សានេះ អ្នកស្រាវជ្រាវសូមផ្តល់ជាអនុសាសន៍មួយចំនួនដូចខាងក្រោម៖

- **ចំពោះសាមីខ្លួននិស្សិត៖**

  និស្សិតគួរតែស្វែងរកឱកាសឱ្យបានច្រើនក្នុងការចូលរួមការស្រាវជ្រាវបែបវិទ្យាសាស្ត្រ អាចជាការចូលរួមក្នុងសកម្មភាពសិក្សា ឬសកម្មភាពស្រាវជ្រាវពីស្ថាប័នផ្សេង ព្រោះអាច (ទី១) និស្សិតអាចមានឱកាសក្នុងការ អនុវត្តន៍ចំណេះដឹងដែលមាន សិក្សាស្វែងយល់ពីការស្រាវជ្រាវចេញពីការងារជាក់ស្តែង ដែលអាចធ្វើឱ្យមូលដ្ឋានចំណេះដឹងរបស់គេមានភាពរឹងមាំ និង (ទី២) បង្កើតនូវទំនាក់ទំនងក៏ដូចជាឱកាសការងារទាក់ទងនឹងការស្រាវជ្រាវ។

- **សម្រាប់សាស្ត្រាចារ្យនិងសាកលវិទ្យាល័យ៖**

  សាកលវិទ្យាល័យគួររៀបចំកម្មវិធីសិក្សាយ៉ាងណា ឱ្យនិស្សិតអាចមានឱកាសកាន់តែច្រើនក្នុងការអនុវត្តចំណេះដឹងទាក់ទងនឹងការស្រាវជ្រាវឱ្យបានទូលំទូលាយ ជាជាងរៀនតែទ្រឹស្តី។

  សាស្ត្រាចារ្យ គួរព្យាយាមរៀបចំកិច្ចការសាលាដោយផ្តល់ឱកាសឱ្យនិស្សិតអាចប្រើប្រាស់ចំណេះដឹងទាក់ទងនឹងការស្រាវជ្រាវ ដើម្បីបំពេញនូវតម្រូវការកិច្ចការជាក់ស្តែង។

- **សម្រាប់វិសាលភាពនៃការស្រាវជ្រាវ៖**

  ដោយសារតែការសិក្សានេះគ្រាន់តែជាករណីសិក្សាតូចមួយ ដូចនេះលទ្ធផលនៃការសិក្សាអាចនឹងមិនឆ្លុះបញ្ចាំងទៅលើស្ថានភាពទូទៅនៃនិស្សិតកម្ពុជានោះទេ។ ជាអនុសាសន៍ គួរតែពង្រីកការសិក្សាទៅលើសាកលវិទ្យាល័យនានាទូទាំងប្រទេសកម្ពុជា ព្រមទាំងពង្រីកវិសាលភាពនៃខ្លឹមសារស្រាវជ្រាវ ក៏ដូចជាការជ្រើសរើសគម្រូសំណាកដែលមានគ្រប់កម្រិតសិក្សានៅថ្នាក់ឧត្តមសិក្សា ដើម្បីឱ្យលទ្ធផលកាន់តែមានភាពស៊ីជម្រៅ។

# ឯកសារយោង

Babbie, E. (2008). The basics of social research fourth edition. *International student edition. Thomson Wadsworth, USA*.

Eam, P. (2017). A study on the Relationship between Research Ability and Mindset of Cambodian Faculty Members and Their Research Outputs: A perspective from Fifteen Higher Education Institutions (Doctoral dissertation, Hiroshima University).

Foskett, N., Roberts, D., & Maringe, F. (2006). *Changing fee regimes and their impact on student attitudes to higher education*. Southampton: University of Southampton.

Gunuc, S. (2014). The relationships between student engagement and their academic achievement. *International Journal on New Trends in Education and Their Implications*, *5*(4), 216-231.

Hajdarpasic, A., Brew, A., & Popenici, S. (2011). *Report on Undergraduate Awareness, Experiences and Perceptions of Research at Macquarie University*. Macquarie University.

Jusoh, R., & Abidin, Z. Z. (2012). The Teaching-Research nexus: A study on the students´ awareness, experiences and perceptions of research. *Procedia-Social and Behavioral Sciences*, *38*, 141-148

Kaing, S. (2017). Students´ Perception of Quality of Teaching in Higher Education in Cambodia (Master thesis, VRIJE Universiteit Brussel)

Lei, H., Cui, Y., & Zhou, W. (2018). Relationships between student engagement and academic achievement: A meta-analysis. *Social Behavior and Personality: an international journal*, *46*(3), 517-528.

Leng, P. (2010). *Students' perceptions toward private sector higher education in Cambodia* (Doctoral dissertation, Ohio University).

MOEYs. (2010). Policy on Research Development in the Education Sector. Retrieved on 25th September, 2019 from http://www.moeys.gov.kh/index.php/en/policies-and-strategies/policy-on-research-development-in-education-sector.html#.XZK9BlUzbIU.

Owlcation. (2019). 7 Reasons why Research in Important. Retrieved on 25th September, 2019 from https://owlcation.com/academia/Why-Research-is-Important-Within-and-Beyond-the-Academe.

QuestionPro. (2019). What is Research – Definition Methods, Types & Examples. Retrieved on 16th September, 2019 from https://www.questionpro.com/blog/what-is-research/.

Royal University of Phnom Penh. (2019). Faculty of Social Science and Humanities. Retrieved on 19th September, 2019 from http://www.rupp.edu.kh/.

Universalclass. (2019). The Importance of Research. Retrieved on 14th September , 2019 from https://www.universalclass.com/articles/writing/reference-skills/the-importance-of-research.htm.